របាយការណ៍សង្ខេប
ស្តីពី
លទ្ធផលសកម្មភាពការងារ
ប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២២

កិច្ចប្រជុំរួមប្រចាំខែមិថុនា ឆ្នាំ២០២២

ថ្ងៃចន្ទ ៦កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦
ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២២

បង្ហាញដោយ **បណ្ឌិត ឈឹម ឃិនជារ៉ែត**
អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

មាតិកានុក្រម

១ សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

២ សកម្មភាពការងារចម្បងៗ និងលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋាន

៣ លទ្ធផលកិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ លើកទី១ ឆ្នាំ២០២២

៤ បញ្ហាប្រឈម

៥ ទិសដៅអនុវត្តបន្ត

១

សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការងារមន្ត្រីទេសកិច្ចក្នុង

- ឯកឧត្តមទេសរដ្ឋមន្ត្រី បានពិនិត្យ និងសម្រេចលើសកម្មភាពនានារបស់ អ.ជ.ប.ជ.អ។
- ឯកឧត្តមទេសរដ្ឋមន្ត្រី បានជួបប្រជុំពិភាក្សាការងារបច្ចេកទេសជាមួយថ្នាក់ដឹកនាំរបស់ អ.ជ.ប.ជ.អ និងបានផ្តល់អនុសាសន៍ពីនីតិវិធីឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ព្រមទាំងលើកទិសដៅផែនការសកម្មភាពរបស់ អ.ជ.ប.ជ.អ។
- បានអញ្ជើញក្នុងពិធីបើកឯកសារដេញថ្លៃ ស្តីពីការបោះពុម្ពសៀវភៅអំពីវិស័យអេដស៍ ពិគ្រោះថ្លៃ ស្តីពីការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រេងរំអិល

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចាត់តួនាទីភារកិច្ច (ត)

ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធី ប្រគល់-ទទួល Laptops, Desktops និងPrinters ពីសប្បុរសជន ដែលជាក្រុមវេជ្ជបណ្ឌិត។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចាប់មគ្គុទ្ទេសក៍ផ្ទៃក្នុង (ត)

ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២២ បានអនុញ្ញាតឱ្យ លោកស្រី Patricia Ongpin នាយិកាថ្មីរបស់អង្គការសហប្រជាជាតិស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ (UNAIDS) ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ប្រទេសឡាវ និងប្រទេសម៉ាឡេស៊ី ចូលមកជើម្បីសម្តែងការគួរសម និងផ្លាស់ប្តូរបទពិសោធន៍របស់អង្គការ UNAIDS ក្នុងឱកាសដែលលោកស្រី ចូលមកកាន់តំណែងថ្មីនៅកម្ពុជា។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចាប់មគ្គុទ្ទេសក៍ផ្ទៃក្នុង (ត)

ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត ។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចាប់មគ្គុទ្ទេសក៍ផ្ទៃក្នុង (ត)

ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២២ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំស្តីអំពីការចែករំលែកបទពិសោធន៍របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាមួយក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាជាតិគាំពារសង្គម។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចារមគ្គុទ្ទេសក៍ផ្ទៃក្នុង (ត)

ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ បានអញ្ជើញជាគណៈអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីខួបលើកទី៤៥ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពត និងសម្ពោធសមិទ្ធផលនានានៅតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្ម។

ឯកឧត្តមទេសរដ្ឋមន្ត្រី

១- ការចាប់មគ្គុទ្ទេសក៍ផ្ទៃក្នុង (ត)

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២។

ឯកឧត្តម គង់ រដ្ឋា

- ពិនិត្យ និងផ្តល់យោបល់ប្រចាំថ្ងៃលើគ្រប់ឯកសារ មុនដាក់ជូនឯឧ ទេសរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច។
- ពិនិត្យ និងចុះហត្ថលេខាលើបេសកកម្ម របាយការណ៍បេសកកម្ម របស់ថ្នាក់ដឹកនាំ និងមន្ត្រី។
- បានចូលរួមប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភា។
- ពិនិត្យបញ្ជីវត្តមាន ថ្នាក់ដឹកនាំ និងមន្ត្រីប្រចាំថ្ងៃ
- ដឹកនាំប្រជុំគណៈកម្មាការកំណត់លក្ខណៈសម្បត្តិ របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូរ សម្រាប់ធ្វើការវាយតម្លៃ និងផ្តល់ពិន្ទុ ដាក់ជូន ឯឧទេសរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច។

ឯកឧត្តម គង់ រដ្ឋា

- បានចូលរួមដឹកនាំកិច្ចប្រជុំដើម្បីបែងចែកការកិច្ចទទួលខុសត្រូវក្នុងការរៀបចំកិច្ចប្រជុំពេញអង្គ។
- បានចូលរួមប្រជុំថ្នាក់ដឹកនាំចង្អៀត។
- បានអញ្ជើញចូលរួមក្នុងពិធី ប្រគល់-ទទួល Laptops, Desktops និងPrinters ពីសប្បុរសជនដែលជាក្រុមវេជ្ជបណ្ឌិត។
- បានអញ្ជើញក្នុងពិធីបើកឯកសារដេញថ្លៃ ស្តីពីការបោះពុម្ពសៀវភៅអំពីវិស័យអេដស៍
- បានអញ្ជើញក្នុងពិធីពិគ្រោះថ្លៃស្តីពីការផ្តត់ផ្តង់ប្រេងឥន្ធនៈ ប្រេងរំអិល និងការផ្តត់ផ្តង់ការជួសជុលរថយន្តសម្រាប់ប្រើប្រាស់ ឆ្នាំ២០២២។

ឯកឧត្តម គង់ រដ្ឋា

- **ផែនការសកម្មភាពសម្រាប់ខែបន្ទាប់**
- ពិនិត្យពង្រឹងរបៀបរបបការងារដែលបានណែនាំរួចហើយ។
- ពង្រឹងវត្តមាន មន្ត្រីថ្នាក់ដឹកនាំ

សំណូមពរ

ពង្រឹងវិន័យ វត្តមាន និងរបាយការណ៍ ឲ្យបានទាន់ពេលវេលា និងមានការទទួលខុសត្រូវ។

ឯកឧត្តម ជា ផលា

១-សកម្មភាពលើកគម្រោងមូលនិធិសកល

- បានសម្របសម្រួលវគ្គបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តកំពង់ចាម ខេត្តសៀមរាប។
- បានចុះពិនិត្យមើលការរៀបចំសេវាមេត្រីនៃគ្លីនីកសុខភាពគ្រួសារ(រួមទាំងការផ្តល់សេវាPrEP)។
- បានចុះពិនិត្យមើលដំណើរការការផ្តល់ប័ណ្ណសមធម៌សុខភាពសម្រាប់អ្នកជំងឺអេដស៍ នៅរាជធានីភ្នំពេញ។
- បានចូលរួមប្រជុំជាមួយក្រុមការងារត្រួតពិនិត្យពាក់កណ្តាលអាណត្តិយុទ្ធសាស្ត្រឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។
- បានដឹកនាំនិងគ្រប់គ្រងសកម្មភាពនៅក្នុងគម្រោង NAA SSI HIV Grant 2021-2023។

ឯកឧត្តម ជា ផលា (ឥ)

២-កិច្ចសហការជាមួយដៃគូអភិវឌ្ឍ

២.១-UNAIDS

- រៀបចំសិក្ខាសាលាពីរ ១)Consultative Workshop on Development of Explanatory Notes for Law on Prevention and Control of HIV and AIDS និង ២) Consultative Workshop on Social Contracting
- បានកែសម្រួលសុន្ទរកថា ឯកឧត្តម ទេសរដ្ឋមន្ត្រី សម្រាប់សិក្ខាសាលា Consultative Workshop on Development of Explanatory Notes for Law on Prevention and Control of HIV and AIDS។

ឯកឧត្តម ជា ផលា (ត)

២-កិច្ចសហការជាមួយដៃគូអភិវឌ្ឍ

២.២-អង្គការ LHSS /USAID

បានចូលរួមបើកវគ្គ និងសម្របសម្រួលកិច្ចប្រជុំរៀបចំផែនសកម្មភាពក្នុងការអនុវត្តគំនិតផ្តួចផ្តើម ទីក្រុងពន្លឿនឆ្លើយតបនឹងមេរោគអេដស៍ នៅរាជធានីភ្នំពេញ។

៣-កិច្ចប្រជុំផ្សេងៗជាបន្ត

- បានរៀបចំបទបង្ហាញស្តីអំពីលទ្ធផលនៃការប៉ាន់ស្មានថ្នាក់ក្រោមជាតិ និងការឈានទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ។
- បានចូលរួមប្រជុំនិងផ្តល់យោបល់ក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត។
- បធ្វើទបង្ហាញស្តីអំពីការសម្របសម្រួលបញ្ចប់អេដស៍ ក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១។

៤-ការងារបណ្តុះបណ្តាល

- បានធ្វើបទបង្ហាញចែករំលែកបទពិសោធន៍ស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាមួយក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាជាតិគាំពារសង្គម។
- បានបង្រៀន កម្មវិធីបណ្តុះបណ្តាលស្តីពី "ការគ្រប់គ្រង និង ភាពជាអ្នកដឹកនាំ"

លោកជំទាវ ស៊ឹម ខេងខាំ

- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភា ឆ្នាំ២០២២។
- ចូលរួមកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២២។

ឯកឧត្តម ស៊ឹម គឹមសៃន

- បានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភា។
- បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការរៀបចំចងក្រងសារ និងត្រួតពិនិត្យសារស្តីពីមេរោគអេដស៍ និងជំងឺអេដស៍លើកទី១។
- **ផែនការសកម្មភាពសម្រាប់ខែបន្ទាប់**
- ត្រៀមធ្វើការងារតាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

ឯកឧត្តម តែង គន្ធី

- ចូលរួមកិច្ចប្រជុំប្រចាំខែរបស់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សម្របសម្រួលការងារក្រុមបុរសរួមភេទជាមួយបុរស និងប្លែងភេទ នៅខេត្តសៀមរាប និងទីក្រុងភ្នំពេញ។
- ចូលរួមប្រជុំចង្អៀតថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឯកឧត្តម រស់ សីលវ៉ាត់

- ចូលរួមប្រជុំថ្នាក់ដឹកនាំប្រចាំខែមេសា ឆ្នាំ២០២២។
- ចូលរួមប្រជុំវាយតម្លៃ ការអនុវត្តឆ្លើយតបនឹងការរាលដាលមេរោគអេដស៍របស់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ។
- ចូលរួមប្រជុំគណៈយោសនាអប់រំ គណបក្សប្រជាជនកម្ពុជា។
- ពិនិត្យ និងផ្តល់ចំលើយតបនឹងសំនើរបស់អគ្គលេខាធិការដ្ឋានស្ថានិតិសម្បទា និងអភិវឌ្ឍន៍ នៃក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា លើសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២១។
- ពិភាក្សាលើការរៀបចំកិច្ចប្រជុំប្រឹក្សាយោបល់ស្តីពីកិច្ចសន្យារហិរញ្ញប្បទានសង្គមកិច្ច និងប្រឹក្សាយោបល់ ស្តីពីលក្ខខណ្ឌ អាយុសម្រាប់ផ្តល់ការយល់ព្រមធ្វើតេស្តឈាមរកមេរោគអេដស៍។

ឯកឧត្តម រស់ សីលវ៉ាត់

- ភាក្សាគម្រោងរៀបចំសិក្ខាសាលាប្រឹក្សាយោបល់គោលនយោបាយកិច្ចសន្យាសង្គម។
- ប្រជុំក្រុមការងារវាយតម្លៃការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍របស់រាជធានីខេត្ត ក្រសួងស្ថាប័នថ្នាក់ជាតិ ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលចំនួន២លើក។
- ចូលរួមអមឯកឧត្តមទេសរដ្ឋមន្ត្រី ក្នុងជំនួបស្វាគមន៍ប្រធានអង្គការយូអិនអេដស៍ថ្មី។
- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត
- ផ្តល់ធាតុចូលលើសេចក្តីព្រាងរបាយការណ៍កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភា២០២២របស់ខុទ្ទកាល័យ។
- ចូលរួមកិច្ចប្រជុំចែករំលែកបទពិសោធន៍ស្តីពីការគ្របដណ្តប់ជាសាកលនូវសេវាសុខាភិបាលដែលដឹកនាំសម្របសម្រួលដោយក្រុមការងារអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម។

ឯកឧត្តម រស់ សីលវ៉ាត់ (ត)

- ផ្តល់យោបល់លើឯកសារសារអប់រំ បង្ការថែទាំ ព្យាបាលអេដស៍ អង្គការខាន់ណា ជូនឯកឧត្តមប្រធានដើម្បីពិនិត្យនិងធ្វើការសម្រេច។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ចូលរួមផ្តល់ធាតុចូលដល់សេចក្តីព្រាងផែនការវិនិយោគបីឆ្នាំរំកិលដែលអគ្គលេខាធិការដ្ឋានកំពុងរៀបចំ សម្រាប់បញ្ជូនទៅក្រសួងផែនការ។
- រៀបចំសិក្ខាសាលាប្រឹក្សាយោបល់លើគំនិតផ្តួចផ្តើមគោលនយោបាយកិច្ចសន្យាសង្គម។

ឯកឧត្តម ជា ពៅ

- ចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមេសា។
- ពិនិត្យសេចក្តីព្រាងសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២២។
- បានផុសក្នុងហ្វេសបុកផេកសរុបចំនួន ៩ដង ត្រឹមថ្ងៃទី២៣ ខែមិថុនាឆ្នាំ២០២២។

សំណូមពរ

ស្នើសុំថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសទាំងអស់ ដែលបានចុះបំពេញការងារ សិក្ខាសាលា កិច្ចប្រជុំផ្សេងៗ ជួយផ្តល់អត្ថបទព័ត៌មានខ្លី ភ្ជាប់ជាមួយរូបភាព ដើម្បីយកមកផុសក្នុង Facebook Page អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ឯកឧត្តម ហោ ប៊ុនឡេង

- បានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែឧសភា
- បានរៀបចំរបាយការណ៍កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមេសាជាភាសាអង់គ្លេស។
- បានពិនិត្យរបាយការណ៍កិច្ចប្រជុំថ្នាក់ថ្នាក់ដឹកនាំប្រចាំខែឧសភា ឆ្នាំ២០២២ ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន។
- បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត។
- បានបកប្រែសុន្ទរកថា បើកនិងបិទ សម្រាប់កិច្ចប្រជុំពេញអង្គ គោរពជូនឯកឧត្តមទេសរដ្ឋមន្ត្រី។
- បានចូលរួមប្រជុំក្រុមការងារឥស្សរជនឆ្នើមថ្នាក់ជាតិក្នុងការរៀនចំគម្រោងផែនការផ្សព្វផ្សាយតាមវិទ្យុជាតិកម្ពុជា។

ឯកឧត្តម ហោ ប៊ុនឡេង (ត)

- បានដឹកនាំកិច្ចប្រជុំគណៈកម្មការរៀបចំ ចងក្រងសារនិងត្រួតពិនិត្យសារស្តីពីមេរោគអេដស៍និងជំងឺអេដស៍។

ផែនការសកម្មភាពសម្រាប់ខែបន្ទាប់

- ត្រៀមចូលរួមកិច្ចប្រជុំបច្ចេកទេសប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- តាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

ឯកឧត្តម ស៊ឹម គឹមសាន

- បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រចាំខែមេសា។
- បានចូលរួមសិក្ខាសាលាស្តីពី ការធ្វើផែនការ និងថវិកា សម្រាប់អនុវត្តន៍សកម្មភាពមេរោគអេដស៍ នៃទីក្រុងពន្លឿនការឆ្លើយតបអេដស៍របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ ។
- បានចូលរួមកិច្ចប្រជុំគណៈកម្មការរៀបចំចងក្រងនិងត្រួតពិនិត្យសារស្តីពីមេរោគអេដស៍និងជំងឺអេដស៍
- **ផែនការសកម្មភាពសម្រាប់ខែបន្ទាប់**
- តាមដាន និងជួយគាំទ្របច្ចេកទេសទៅដល់ក្រសួង និងខេត្តទទួលខុសត្រូវ។

២

សកម្មភាពការងារចម្បងៗ និងលទ្ធផលការងារ

របស់អគ្គលេខាធិការដ្ឋាន

សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

- ថ្ងៃទី៨ ខែមិថុនា បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស បូកសរុបការងារជាក់បញ្ជាលការឆ្លើយតបមេរោគអេដស៍ និងដំងឺអេដស៍ ទៅក្នុងផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ នៃខេត្ត FTC ទាំង៤ នៅខេត្តកំពង់ចាម។
- ព្រឹកថ្ងៃទី៧ ខែមិថុនា ដឹកនាំកិច្ចប្រជុំបច្ចេកទេសអគ្គលេខាធិការដ្ឋាន។
- នៅថ្ងៃទី០៨-១០ ខែមិថុនា បានចុះអភិបាលកិច្ចស្វែងយល់ពីការងារសមាហរណកម្មកម្មវិធីអេដស៍ និងអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងការអភិវឌ្ឍផែនការឃុំ សង្កាត់។
- ព្រឹកថ្ងៃទី១៣ ខែមិថុនា ចូលរួមទទួលវិញ្ញាណបនបត្របញ្ចប់វគ្គសិក្សាអ្នកដឹកនាំ និងនានុវត្តន៍ ក្នុងពិធីបិទវគ្គចែកសញ្ញាបត្រ វិញ្ញាបនបត្រ និងបើកវគ្គបណ្តុះបណ្តាល ឆ្នាំ២០២២ របស់សាលាភូមិន្ទរដ្ឋបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- រសៀលថ្ងៃទី១៣ ខែមិថុនា ចូលរួមកិច្ចប្រជុំគណៈកម្មការរៀបចំកិច្ចប្រជុំពេញអង្គលើកទី១ ក្រោមអធិបតី ឯកឧត្តមអនុប្រធានប្រចាំការ។
- ព្រឹកថ្ងៃទី១៤ ខែមិថុនា ដឹកនាំកិច្ចប្រជុំមន្ត្រីអគ្គលេខាធិការដ្ឋានពិនិត្យការងារត្រៀមរៀបចំកិច្ចប្រជុំពេញអង្គលើកទី១។
- ព្រឹកថ្ងៃទី១៥ ខែមិថុនា បានចូលរួមកិច្ចប្រជុំថ្នាក់ដឹកនាំចង្អៀត ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី**។

សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

- នៅថ្ងៃទី១៤ និង១៥ ខែមិថុនា លោកជំទាវអគ្គលេខាធិការរងបានចូលរួមសិក្ខាសាលាស្តីពីការអនុវត្តរបស់កម្ពុជាលើផែនការសកម្មភាព មហាអនុតំបន់មេគង្គខមមីត (Commit : Coordinated Mekong Ministerial Initiative Against Trafficking)ទី៤ និងពិគ្រោះយោបល់ ថ្នាក់ជាតិលើកទី១លើ ការរៀបចំ យន្តការបញ្ជូនឆ្លងដែនរបស់ក្រសួងកិច្ចការនារីនៅកាបូឌីយ៉ាណាក្រោម អធិបតីភាព **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** និងមានវត្តមាន ចូលរួមពីក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធសរុបចំនួនប្រមាណ ៧០នាក់។
- នៅថ្ងៃទី១៦-១៧ ខែមិថុនា បានរៀបចំសិក្ខាសាលាប្រចាំឆ្នាំចែករំលែកបទពិសោធន៍ស្តីពីសមាហរណកម្មសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍឃុំ-សង្កាត់ នៅខេត្តកំពង់ធំ។
- ថ្ងៃទី២០ ខែមិថុនា ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦ ពិនិត្យ ពិភាក្សា និងឯកភាពលើរបាយការណ៍របាយការណ៍វឌ្ឍនភាពស្តីពីការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០២២។
- ថ្ងៃទី១៧ ខែមិថុនា ចូលរួមក្នុងកិច្ចប្រជុំស្តីអំពីការចែករំលែកបទពិសោធន៍របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ជាមួយក្រុមការងារបច្ចេកទេសនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមទេសរដ្ឋមន្ត្រី**។
- ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ សិក្ខាសាលាស្តីពីការរៀបចំផែនការ និងថវិកាសម្រាប់អនុវត្តសកម្មភាពមេរោគអេដស៍នៃទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តមអនុប្រធានទទួលបន្ទុកបច្ចេកទេស នៅភោជនីយដ្ឋានទន្លេបាសាក់២។

សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

- នៅរសៀលថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២ ដឹកនាំកិច្ចប្រជុំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងផែនការថវិកាឆ្នាំ២០២៣ បានបញ្ជូនទៅក្រសួងសុខាភិបាលនៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២។
- ថ្ងៃទី២២ ដល់ទី២៤ ខែមិថុនា ឆ្នាំ២០២២ រៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិស ក្នុងការដាក់បញ្ចូលការងារអេដស៍ទៅក្នុងផែនការ៣ឆ្នាំរំកិល ដល់ថ្នាក់ឃុំ សង្កាត់ នៅខេត្តសៀមរាប។
- ព្រឹកថ្ងៃទី២៤ ខែមិថុនា ចូលរួមកិច្ចប្រជុំលើកទី១ គណៈកម្មការរៀបចំ ចងក្រង និងត្រួតពិនិត្យសារស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ (លិខិតបង្គាប់ការលេខ០១១ អ.ជ.ប.ជ.អ ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២២)
- ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ដឹកនាំកិច្ចពិភាក្សាសេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍របស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ ក្នុងកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ រាជធានីភ្នំពេញ នៅសាលប្រជុំសាលារាជធានីភ្នំពេញ។
- ថ្ងៃទី២៧-២៩ ខែមិថុនា ឯកឧត្តមអគ្គលេខាធិការរង ០៣រូប ចុះបំពេញបេសកកម្មនៅខេត្តពោធិ៍សាត់ក្រោមមូនិធិសកល ដើម្បីស្វែងយល់ និងណែនាំដល់ការងារសមាហរណកម្មមេរោគអេដស៍ចូលក្នុងឃុំ សង្កាត់។
- ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ បានចូលរួមរៀបចំកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមទេសរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។

សកម្មភាពរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

- ថ្ងៃទី២៣-២៥ ខែមិថុនា បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងពីសមាហរណកម្មសកម្មភាពឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដែលរៀបចំដោយអង្គការLHSS នៅសណ្ឋាគារ ក្លាស៊ី ខេត្តបាត់ដំបង។
- បានរៀបចំសុន្ទរកថាបើក និងសុន្ទរកថាបិទជូន ឯកឧត្តមទេសរដ្ឋមន្ត្រី សម្រាប់ថ្លែងក្នុងកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ២០២២។
- រៀបចំសេចក្តីព្រាងសេចក្តីសម្រេចចិត្ត នៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១ ឆ្នាំ ២០២២។
- អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានរៀបចំលិខិតសំណើសុំអន្តរាគមន៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់ថវិកាចំនួន ៦០.០០០.០០០រៀល ជូនខេត្តចំនួន១១ (កណ្តាល តាកែវ ព្រៃវែង កំពង់ចាម ពោធិ៍សាត់ កំពង់ស្ពឺ ព្រះសីហនុ ត្បូងឃ្មុំ កំពង់ឆ្នាំង ប៉ៃលិន និងកំពង់ធំ) និងបានទំនាក់ទំនងធ្វើកិច្ចការនេះ ជាមួយអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- រៀបចំសម្របសម្រួលការងាររដ្ឋបាលនានា។

៣

លទ្ធផលកិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ លើកទី១ ឆ្នាំ២០២២

សមាជិកជាគណៈកម្មាធិការក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការដៃគូ ចូលរួមចំនួន១៦០នាក់

បានអនុម័តចេញសេចក្តីចិត្តជាយុទ្ធសាស្ត្រ ចំនួន៩ចំណុច សម្រាប់ដាក់ឲ្យអនុវត្តន៍៖

1. ជំរុញលើកទឹកចិត្តដល់ គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ស្ថាប័ រាជធានី ខេត្ត ដំណើរការលើកផែនការសកម្មភាព និងគម្រោងថវិការបស់ខ្លួន ឱ្យស្របជាមួយនឹងពេលវេលា នៃការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ ស្របតាមផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺ អេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ ដោយផ្តោតលើអនុសាសន៍នៃការវាយតម្លៃផែនការយុទ្ធសាស្ត្រពាក់កណ្តាលអាណត្តិ និងស្របតាមអាណត្តិការងាររបស់ស្ថាប័នសាមី និងសូមការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
2. លើកទឹកចិត្តក្រសួងទេសចរណ៍ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជំរុញអនុវត្តគោលនយោបាយស្រោមអនាម័យ ១០០ភាគរយ នៅតាមកន្លែងឧស្សាហកម្មសណ្ឋាគារ ដូចជា សណ្ឋាគារ ប៉ៀរហ្គាដិន ខារ៉ាអូខេ និងទីកន្លែងកម្សាន្តនានា។
3. លើកទឹកចិត្តក្រសួងសុខាភិបាល (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក) ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យជំរុញការផ្តល់សេវាបង្ការ ការពារ ថែទាំ កាត់បន្ថយការចម្លងមេរោគអេដស៍ ពីមាតាទៅទារក ឱ្យបានតាមគោលដៅកំណត់។
4. ជំរុញការរៀបចំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដោយបញ្ចូលសមាសភាពពាក់ព័ន្ធនានា តំណាងអ្នកផ្ទុកមេរោគអេដស៍ តំណាងប្រជាជនគន្លឹះ បន្ថែមទៅក្នុងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ (គ.ក.ន.ក.)។
5. ជំរុញលើកទឹកចិត្តមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ និងអង្គការដៃគូអភិវឌ្ឍន៍ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល រៀបចំវិធីសាស្ត្រ និងមធ្យោបាយប្រកបដោយនវានុវត្តន៍ និងបរិយាប័ន្ន ដើម្បីឱ្យក្រុមប្រជាជនគន្លឹះ ៩៥ភាគរយ ទទួលបាននូវសេវាបង្ការចម្រុះរួម ចៀសផុតពីការឆ្លងមេរោគអេដស៍។

សមាជិកជាគណៈកម្មាធិការក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការដៃគូ ចូលរួមចំនួន១៦០នាក់

6. ជំរុញលើកទឹកចិត្តក្រសួងសុខាភិបាល (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ) ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការដៃគូស្វែងរក និងបញ្ចុះបញ្ចូលឱ្យអ្នកផ្ទុកមេរោគអេដស៍ប្រមាណ ១២.០០០នាក់ ដែលមិនទាន់មកទទួលសេវាព្យាបាល ឱ្យមកទទួលធ្វើតេស្តរកមេរោគអេដស៍ ដើម្បីទទួលបានសេវាថែទាំ និងព្យាបាលឱ្យបានទាន់ពេល។
7. ជំរុញលើកទឹកចិត្តក្រសួងសុខាភិបាល (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ) និងអង្គការដៃគូ ឱ្យពង្រីកតំបន់គ្របដណ្តប់ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាប្រើប្រាស់វិធីលេបថ្នាំបង្ការទុកជាមុន នៅពេលប្រព្រឹត្តប្រឈមនឹងការចម្លងមេរោគអេដស៍ (Pre-exposure prophylaxis, PrEP) ដល់ប្រជាជនគន្លឹះ។
8. ស្នើសុំមូលនិធិសកល (Global Fund) តាមរយៈគណៈកម្មាធិការសម្របសម្រួលជំនួយមូលនិធិសកល ដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់នៅកម្ពុជា (CCC) និងដៃគូអភិវឌ្ឍទាំងអស់ ជួយពង្រឹងសមត្ថភាពស្ថាប័ន ដែលផ្តួចផ្តើមដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីឆ្ពោះទៅសម្រេចចីរភាពកម្មវិធីអេដស៍នៅកម្ពុជា។
9. ជំរុញដល់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការផ្តល់ធាតុចូលពីក្រុមប្រឹក្សាជាតិគាំពារសង្គម រៀបចំគោលនយោបាយជាតិស្តីពីកិច្ចសន្យាសង្គម (Social contracting) ដើម្បីអនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលកំពុងធ្វើការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ អាចជួយធ្វើអន្តរាគមន៍លើការងារឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងពេលអនាគត តាមការចាំបាច់។

៤

បញ្ហាប្រឈម

ឧបសគ្គចម្បង

- កង្វះថវិកាសម្រាប់ដំណើរការកិច្ចប្រជុំការបង្កើតក្រុមការងាររៀបចំ ត្រួតពិនិត្យ វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ (សេចក្តីសម្រេចលេខ ១៦២ អ.ជ.ប.ជ.អ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២)។
- ការពង្រីក និងពង្រឹងការងារជាពហុវិស័យស្របតាមតួនាទី ដែលបានចែងក្នុងច្បាប់បាប់ស្តីពីការបង្ការ និងប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) និងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ទាមទារការសាមគ្គី ឯកភាព សមត្ថភាព បែបបទការងារ និងការប្រើប្រាស់ធនធានកាន់តែមាននវានុវត្តន៍ បរិយាប័ន្ន និងប្រសិទ្ធភាពជាងមុន។

៥

ទិសដៅអនុវត្តបន្ត

ទិសដៅអនុវត្តបន្ត

- បន្តអនុវត្តសកម្មភាពតាមផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ. ឆ្នាំ២០២២។
- បន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យការអនុវត្តសជណ២១៣ តាមបណ្តារាជធានី ខេត្តគោលដៅ។
- បន្តសហការរៀបចំផែនការយុទ្ធសាស្ត្រទីក្រុងពន្លឿនការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តាមបណ្តា រាជធានី ខេត្តគោលដៅ។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី៧ លើរបៀបវារៈ "យន្តការពង្រីកតំបន់គ្របដណ្តប់ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាប្រើប្រាស់វិធីលេបថ្នាំបង្ការទុកជាមុន នៅពេលប្រព្រឹត្តប្រឈមនឹងការចម្លងមេរោគអេដស៍ (Pre-exposure prophylaxis, PrEP) ដល់ប្រជាជនគន្លឹះ"។
- រៀបចំលិខិតជូនគណៈរដ្ឋមន្ត្រី សំណើសុំរៀបចំអនុក្រឹត្យស្តីពីការប្រុងប្រយ័ត្នជាសកល ចំពោះការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS)។
- បន្តធ្វើការងារជាមួយអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការផ្តល់ថវិកាជូន ខេត្តទាំង១១។
- បន្តធ្វើការងារជាមួយអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើប្រកាសស្តីពីវិធាន និងនីតិវិធីចំណាយសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងកិច្ចប្រជុំសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសស្តីពីវិធាន និងនីតិវិធីចំណាយបេសកកម្មក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- បំពេញការងារផ្សេងៗតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី។

សូមអរគុណ!